**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...១៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការចាត់ថ្នាក់ផ្ទៃដីព្រៃលិចទឹក ការធ្វើអនុបយោគ និងការប្រគល់អាណត្តិកាន់កាប់ដីរដ្ឋ ស្ថិតក្នុងសង្កាត់រាម និងសង្កាត់បិតត្រាំង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋលេខាធិការអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញប្រកាសលេខ ០០៦៧ បក កសក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៨៩ ស្តីពីការកំណត់នាទីព្រៃលិចទឹកនៅទន្លេសាប និងសមុទ្រ
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**សម្រេច**

**មាត្រា ១ :** ត្រូវបានចាត់ថ្នាក់ផ្ទៃដីព្រៃលិចទឹក ជាផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងក្រៅពីវិស័យជលផល ទំហំពីររយសាមសិបប្រាំពីរហិកតា (២៣៧ ហ.ត) ស្ថិតនៅសង្កាត់រាម និងសង្កាត់បិតត្រាំង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ដែលមាននិយាមការ :

**តំបន់ទី១ :**

1 : 350969, 1168051
2 : 350374, 1167064
3 : 350093, 1166650
4 : 349959, 1166399
5 : 349950, 1165990
6 : 349326, 1165988
7 : 349171, 1166500
8 : 350720, 1169387
9 : 350771, 1169327
10 : 350758, 1169269
11 : 350682, 1169171
12 : 350625, 1169076
13 : 350513, 1168873
14 : 350618, 1168792
15 : 350692, 1168751
16 : 350701, 1168694
17 : 350610, 1168652
18 : 350561, 1168537
19 : 350555, 1168497
20 : 350554, 1168496
21 : 350469, 1168306
22 : 355969, 1168051

**តំបន់ទី២ :**

1 : 350292, 1169749
2 : 350347, 1169771
3 : 350413, 1169747
4 : 350462, 1169681
5 : 350503, 1169722
6 : 350692, 1169928
7 : 350799, 1170051
8 : 350782, 1170117
9 : 350717, 1170183
10 : 350676, 1170215
11 : 350725, 1170298
12 : 350807, 1170232
13 : 350906, 1170215
14 : 350997, 1170347
15 : 351095, 1170322
16 : 351128, 1170257
17 : 351063, 1170158
18 : 350980, 1170125
19 : 350890, 1169993
20 : 351120, 1169829
21 : 351071, 1169796
22 : 350840, 1169837
23 : 350783, 1169837
24 : 350618, 1169582
25 : 350690, 1169504
26 : 350688, 1169504
27 : 350292, 1169749

**មាត្រា ២ :** ត្រូវបានផ្ទេរផ្ទៃដីព្រៃលិចទឹក ទំហំពីររយសាមសិបប្រាំពីរហិកតា (២៣៧ ហ.ត) ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ចេញពីដែននេសាទ ដើម្បីគោលបំណងអភិវឌ្ឍន៍អាកាសយានដ្ឋានអន្តរជាតិកងកេង ។

**មាត្រា ៣ :** ត្រូវបានធ្វើអនុបយោគផ្ទៃដីព្រៃលិចទឹក ទំហំពីររយសាមសិបប្រាំពីរហិកតា (២៣៧ ហ.ត) ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។ ផែនទីបញ្ជាក់ទីតាំង ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ៤ :** ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីរដ្ឋ ជូនរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដើម្បីចុះបញ្ជីជាដីឯកជនរបស់រដ្ឋ ទំហំពីររយសាមសិបប្រាំពីរហិកតា (២៣៧ ហិកតា) ដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះសម្រាប់គោលដៅអភិវឌ្ឍន៍អាកាសយានដ្ឋានអន្តរជាតិកងកេង ។

**មាត្រា ៥ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី រដ្ឋលេខាធិការអាកាសចរស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលក្រុងព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យលោកឧបនាយករដ្ឋមន្ត្រី ស ខេង
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ ✓